# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៣-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៥២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងលោកជំទាវ ចំនួន ៣៣ រូប ២៤៨១

០៣-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៥៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម ឧកញ៉ា អស់លោក និងលោកស្រី ចំនួន ០៤ រូប ២៤៨២

០៣-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៥៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **តាបិ គីយូស៊ី** (TABE KIYOSHI) ជនជាតិជប៉ុន សញ្ជាតិជប៉ុន ២៤៨៣

០៣-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៥៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ចាន់វ៉័យ** (WANG ZHANWEI) ជនជាតិចិន សញ្ជាតិចិន ២៤៨៤

០៣-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៥៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស្វ៊ីវិនគ្រ្គាប៉ះ សាមុយអែល** (SCHWEINGRUBER SAMUEL) ជនជាតិស្វីស សញ្ជាតិស្វីស ២៤៨៥

០៣-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៥៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **សេរីថូរ៉ាណាកុល ស៊ីរីន** (SEREETHORANAKUL SIRIN) ជនជាតិថៃ សញ្ជាតិថៃ ២៤៨៦

០៣-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៥៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សម្តេច ឯកឧត្តម និងលោកជំទាវ ចំនួន ០៧ រូប ២៤៨៧

០៣-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៥៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និង កញ្ញា ចំនួន ១៨ រូប ២៤៨៨

០៣-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក លោកស្រី និង កញ្ញា ចំនួន ២៧ រូប ២៤៨៩

០៤-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **ជូ យ៉ាលីង** (CHOU YA-LING) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ២៤៩០

០៤-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦២ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឆាន មីុង** (CHAN MING) ជនជាតិចិន សញ្ជាតិចិន ២៤៩១

០៤-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦៣ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **យ៉ារីវ ឡឺនណឺ** (YARIV LERNER) ជនជាតិអុីស្រាអែល សញ្ជាតិអុីស្រាអែល ២៤៩២

០៤-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦៤ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ហ្គូ វ៉េ** (GU WEI) ជនជាតិចិន សញ្ជាតិចិន ២៤៩៣

០៤-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦៥ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឃើរី គ្រីសស្តូភើ ហ្គ្រេម** (CURRIE CHRISTOPHER GRAEME) ជនជាតិអង់គ្លេស សញ្ជាតិអង់គ្លេស ២៤៩៤

០៤-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦៦ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ឈឹង ជូយីន** (CHENG, CHOU-YIN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ២៤៩៥

០៤-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦៧ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈឯកឧត្ដម **គីម តារា** ជាទីប្រឹក្សាសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយក ដោយមិនយកប្រាក់បៀវត្ស ២៤៩៦

០៦-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦៨ ស្ដីពី ការតែងតាំងឯកឧត្ដម **ស្រី ណារី** ជាឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ២៤៩៧

០៦-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៦៩ ស្ដីពី ការតែងតាំងឯកឧត្ដម **កេ គិមសែ** ជាឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ២៤៩៨

០៨-០៣-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៣១៦/២៧០ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហានថ្នាក់ឧត្ដមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ២១ រូប ២៤៩៩

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

១៦-០៣-២០១៦ -អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្ដីពី ការប្រែក្លាយមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តព្រះសីហនុ ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ ២៥០១

១៦-០៣-២០១៦ -អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា ២៥០៥

២៥-០២-២០១៦ -អនុក្រឹត្យលេខ ២០៩ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ២៥២០
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៥២៧
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៥២៨
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៥២៩
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៥៣០
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៥៣១
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១៥ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ២៥៣៣
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៥៣៤
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៥៣៥
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៥៣៧
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៥៣៩
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៥៤១
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៥៤២
២៥-០២-២០១៦ -អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៥៤៣
២៦-០២-២០១៦ -អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៥៤៥
២៦-០២-២០១៦ -អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៥៤៦
២៦-០២-២០១៦ -អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ២៥៤៩
២៦-០២-២០១៦ -អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែង និងតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ២៥៥៥

## ២_សេចក្តីសម្រេច

១៤-០៣-២០១៦ -សេចក្តីសម្រេចលេខ ២៤ សសរ ស្តីពី ការបង្កើតសមាសភាពគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ២៥៥៧
១៥-០៣-២០១៦ -សេចក្តីសម្រេចលេខ ២៥ សសរ ស្តីពី ការផ្លាស់ប្តូរសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ២៥៦០
១៥-០៣-២០១៦ -សេចក្តីសម្រេចលេខ ២៦ សសរ ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់រៀបចំមហោស្រពសិល្បៈកំណាព្យ និងចម្រៀងខ្មែរ ជាសាកល ២៥៦២

## III_ការងារបណ្តាក្រសួង

### ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១១-០២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១២០ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់អង្គភាពប្រឆាំងអំពើពុករលួយ ២៥៦៥

១១-០២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១២១ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន របស់អង្គភាពប្រឆាំងអំពើពុករលួយ ២៥៧០

១១-០២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១២២ សហវ.ប្រក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ សម្រាប់បើកប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ជូនមន្ត្រីរាជការនៅ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ២៥៧២

១១-០២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១២៣ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន របស់ក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ២៥៧៤

១១-០២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១២៤ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន នៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ២៥៧៦

១១-០២-២០១៦ -ប្រកាសអន្តរក្រសួងលេខ ១២៥ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ២៥៧៩


### ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


០២-១២-២០១៥ -ប្រកាសលេខ ៦៩៥ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេក្រូ ហ្គាម៉ិន អាយអិនឌី ខប បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ២៥៨៥

០២-១២-២០១៥ -ប្រកាសលេខ ៦៩៦ ឧស.កឧ.ប្រក.១១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូនីប្រូស (ខេមបូឌា) អេនធើប្រាយ បង្កើតសាខារោងចក្រ ផលិតតង់គ្រប់ប្រភេទ ២៥៨៨

០២-១២-២០១៥ -ប្រកាសលេខ ៦៩៧ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សាន់ជយ ហ្វើ ប្រូសេស៊ីង (ខេមបូឌា) បង្កើតរោងចក្រ ផលិតរូបពីរោមសត្វ និងស្បែកសត្វ និងកែច្នៃរោមសត្វ និងស្បែកជាប់រោមសត្វ ២៥៩១

០២-១២-២០១៥ -ប្រកាសលេខ ៦៩៨ ឧស.កឧ.ប្រក.១២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីស៊ីអិមអិម មេទ្ធហ្វេកឈ័រ បង្កើតរោងចក្រ ផ្គុំតម្លើងម៉ូតូ ២៥៩៤

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/២៥២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

## ជូន

ក-គ្រឿងឥស្សរិយយស ជាតូបការ :

១-ឯកឧត្តម យឹម ណុលឡា
២-ឯកឧត្តម សយ សុខា
៣-ឯកឧត្តម ឌុយ ធៅ
៤-ឯកឧត្តម យឹម ណារុបសុន
៥-លោកជំទាវ ឆាយ ម៉ាន់នឿន
៦-ឯកឧត្តម ស្វាយ ស៊ីថា
៧-ឯកឧត្តម ផៃ ស៊ីផាន
៨-ឯកឧត្តម អ៊ុន វីរជាតិ
៩-ឯកឧត្តម តឹកវ៉េត សំរេច
១០-ឯកឧត្តម សុក ផេង
១១-ឯកឧត្តម ថ្វា សុចិន្តា
១២-ឯកឧត្តម ធីយ រឿន
១៣-ឯកឧត្តម ឈួន សុធី
១៤-ឯកឧត្តម ឆៀន ម៉ៅ
១៥-ឯកឧត្តម ចឹម ចិសិដ្ឋ
១៦-ឯកឧត្តម ឃុន ជិនកេន
១៧-ឯកឧត្តម អ៊ុច ខេង

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោកជំទាវ មាសសាវឹម ជានី
២-ឯកឧត្តម ហេ កាន់
៣-ឯកឧត្តម ហេង សិក្សា

គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម ឡេង សេង
២-ឯកឧត្តម ឈឹម សៅគី
៣-ឯកឧត្តម ជាង អេងងួន
៤-ឯកឧត្តម កែម មង្គល
៥-ឯកឧត្តម នេស សុខម៉េង

ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម ហែម ក្រាញ់តូនី
២-ឯកឧត្តម អ៊ុន ប៊ុណ្ណារ៉ា
៣-ឯកឧត្តម ថាច គឹមឡុង
៤-លោកជំទាវ នុង សុគន្ធ
៥-ឯកឧត្តម ឆែម ពេត
៦-ឯកឧត្តម អាន ជាលី
៧-ឯកឧត្តម ហោ ណារិបូរ៉ា

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

ឯកឧត្តម ម៉ាន់ ផល

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧៖ល.១៦០៣.២៥៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦

លេខ: ២៥៧ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/២៥៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

**ក.** គ្រឿងឥស្សរិយយស **ជាតូបការ :**

១-ឯកឧត្តម **យឹម សៀប**

២-ឧកញ៉ា **អេរិច ឌុយវ៉ាល់** ( Eric DUVAL )

**ខ.** គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់**មហាសេនា :**

១-លោក **ចុង ផ្យុងយ៉ុង** ( Mr. JUNG PYUNGYONG )

២-លោកស្រី **ចុង ហេណា** ( Mrs. JEONG HYENA )

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារស.១៦០៣.២៥៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦*

លេខៈ ២៥៥ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៣១៦/៧៥៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **តាបិ គីយ៉ូស៊ី** (TABE KIYOSHI) ជនជាតិជប៉ុន សញ្ញាតិជប៉ុន កើតថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៦ នៅទីក្រុងនិកាតាខិន ប្រទេសជប៉ុន ដោយប្តូរឈ្មោះជា **សុខ រិទ្ធី** (SOK RITHY)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរណ.១៦០៣.៧៥៩

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ២៥៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៣ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/២៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ចាន់វ៉ៃ** (WANG ZHANWEI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧០ នៅខេត្តហ៊ីណាន សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **វ៉ាង ភក្តី** (WANG PHEAKDEY)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១៦០៣.២៦០

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦

លេខ: ២៦០ .ស.ណ
សំណៅចម្លងចែកជូនតាមក្រសួង ស្ថាប័នពាក់ព័ន្ធ
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៣ ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

នស/រកត/០៣១៦/២៥៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊្វិនគ្រូប៊ែរ សាមុយអែល** (SCHWEINGRUBER SAMUEL) ជនជាតិស្វីស សញ្ជាតិស្វីស កើតថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៨ នៅទីក្រុងហ្វ្រាអិនហ្វែល សហព័ន្ធស្វីស ដោយសុំប្តូរឈ្មោះជា **សេម សំណាង** (SAM SAMNANG)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៦០៣.២៦១

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ២៥៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៣១៦/២៥៧

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **សេរីថូរ៉ាណាកុល ស៊ីរីន** (SEREETHORANAKUL SIRIN) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៨៦ នៅរាជធានីបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍ ដោយសុំប្តូរឈ្មោះជា **លី ស៊ីរីន** (LI SIRIN)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រល.១៦០៣.២៦២

លេខ: ២៥៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦*

**សយ សុខា**

នស/រកត/០៣១៦/២៥៤

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

## នូវ

ក-គ្រឿងឥស្សរិយយស **ជាតូបការ** :

១- លោកជំទាវ **ចែម   ទេយ្យរិទ្ធ**        ២- ឯកឧត្តម  **ពិត   តាំងសាន**

៣- ឯកឧត្តម   **ចាន់   រ៉ាស៊ី**

ខ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ផាន់ដារ៉ាវង្ស**   ២- សម្តេចព្រះមហិស្សរា **នរោត្តម ចក្រពង្ស**

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម   **ច័ន្ទ   សុវណ្ណារ៉េត**

ឃ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេនា** :

១- សម្តេច   **នរោត្តម  សិរិវុឌ្ឍ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ព្រសល.០១៦០៣.២៦៣

លេខៈ ៣០១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី   ០៣   ខែ មីនា ឆ្នាំ ២០១៦*

សយ សុខា

នស/រកត/០៣១៦/២៥៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **ព្រហ្ម វិចិត្រសុភា** ២- ឯកឧត្តម **ឯក សំអាត**
៣- ឯកឧត្តម **ចាប ញ៉ារីទុធ** ៤- លោកជំទាវ **ឯក ឆវីវណ្ណា**

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **ផាត់ ពៅស៊ាង** ២- ឯកឧត្តម **ម៉េង គីមលី**

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- ឯកឧត្តម **ឡេង ណារ៉ា** ២- ឯកឧត្តម **អេង សុត្ថាវុទ្ធ**

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- អ្នកម្នាង **មាស ស្រីតុប** ២- លោកជំទាវ **ឯក ម៉ាស៊ីច័ន្ទ**
៣- លោកស្រី **ព្រហ្ម វិចិត្រនារីឧត្តម**

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោកជំទាវ **នូ សំបូរ** ២- លោក **យិន ទីរ:**
៣- លោក **មាស សុភ័ណ្ឌ**

ច-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១- ឯកឧត្តម **គីលីយ៉េង ប្លែស** ២- លោក **ស៊ិន សទ្ធា**
៣- កញ្ញា **លិន លីហ្សា** ៤- កញ្ញា **លិន លីនដា**

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

លេខ: ២៥៩ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

ចារឈ. ១៦០៣.២៦៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/៧៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **អ៊ុំ អិល**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោក **ខណ្ណា សុភ័ក្រ្ត**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

| | |
|---|---|
| ១- កញ្ញា **ស្រ្តេង ពិដោរ** | ២- លោកស្រី **សុខ ខណ្ឌារ៉ែន** |
| ៣- លោក **ស៊ាន សំណាង** | ៤- លោក **សេង សុផា** |
| ៥- លោក **ឈុន សុជាតិ** | ៦- លោក **ប៊ុន សីហៈ** |
| ៧- លោកស្រី **ម៉ឹង ហ៊ាន់ឌី** | ៨- លោក **តាន់ ម៉ាឡា** |
| ៩- លោកស្រី **ធីម ពៅធីតា** | ១០- លោក **សាន សុខា** |
| ១១- លោក **មាស តិរុន** | |

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** :

| | |
|---|---|
| ១- លោក **ស៊ាន សូលីខុង** | ២- លោក **ឡុង សុភ័ក្រ** |
| ៣- លោក **ចាន់ រតនៈ** | ៤- លោក **តាន់ ប៊ុនណាត** |
| ៥- លោក **សេង ខេង** | ៦- លោក **នុត យុទ្ធនា** |
| ៧- លោក **ឆុំ រង្សី** | ៨- លោក **ប៉េង សុខុម** |
| ៩- លោកស្រី **គួ សំនៀង** | ១០- លោក **សក់ សុខាចា** |
| ១១- លោកស្រី **ប៊ិន សោភា** | ១២- លោក **សាន សុផា** |
| ១៣-លោកស្រី **មាស តាលន** | ១៤- លោកស្រី **ហែម បុប្ផា** |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស.១៦០៣.៧៦៥

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ៣០០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/២៦១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **ជូ យ៉ាលីង** (CHOU YA-LING) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៦៥ នៅខេត្តតៃវ៉ាន់ សាធារណរដ្ឋចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរជ. ១៦០៣. ២៦៦

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ២៦១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/៤៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឆាន ម៉ីង** (CHAN MING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨១ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការស. ១៦០៣. ៤៦៧

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦

លេខ: ៥៦២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ ០៣ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/២៦៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ារីវ ឡឺនណឺ** (YARIV LERNER) ជនជាតិអ៊ីស្រាអែល សញ្ជាតិអ៊ីស្រាអែល កើតថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧២ នៅខេត្តហៃហ្វា ប្រទេសអ៊ីស្រាអែល។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣៧.១២០៣.២៦៤

លេខ: ២៦៦. ស.ណ

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦*

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

នស/រកត/០៣១៦/៤៦៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្គូ វៃ** (GU WEI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៦៣ នៅខេត្តលាវនីង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

រកម. ១៦០៣. ៤២៩

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ២៦៣ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៣ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/២៦៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឃើរី គ្រីសស្តូភើ ហ្គ្រែម** (CURRIE CHRISTOPHER GRAEME) ជនជាតិអង់គ្លេស សញ្ជាតិអង់គ្លេស កើតថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៦៦ នៅក្រុងហ្គាតធីស៊ីត ចក្រភពអង់គ្លេស ដោយសុំប្តូរឈ្មោះជា **ច័ន្ទ វីរៈបុត្រ** (CHAN VIREAKBOTH)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៦០៣.២៩៧០

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ២៦៥.ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៣១៦/៤៦៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ឈិន ជូយីន** (CHENG, CHOU-YIN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៥៥ នៅក្រុងតៃប៉ិថ្មី សាធារណរដ្ឋចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១២០៣. ៤៧១

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ៧៦៤ ស.ណ

**សំណៅចម្លងចេញពីសំណៅដើម**
រាជធានីភ្នំពេញ .ថ្ងៃទី ០៧ ខែ ៣/៣ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៣១៦/២៦៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **គីម តារា** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយក ដោយមិនយកប្រាក់បៀវត្ស ។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១០៣.២៧២

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦*

លេខ: ២៦៧ ស.ណ
**សំណៅចំលងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៣ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/២៦៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ត្រាស់បង្គាប់

តែងតាំង

ឯកឧត្តម ស្រី ណូរី

ជា

ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
បន្ថែមលើមុខងារបច្ចុប្បន្ន

ន សីហមុនី

នរោត្តម សីហមុនី

៧រល.១៦០៣.២៧៣

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៦

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ០១៧/១៦ រ. ចច
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៦
សម្ដេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្ដម គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/២៦៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ត្រាស់បង្គាប់**

**តែងតាំង**

**ឯកឧត្តម កេ គិមសែ**

**ជា**

**ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**
**បន្ថែមលើមុខងារបច្ចុប្បន្ន**

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

ចារល. ១៦០៣.២៧៤

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៦*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ០៧៤/១៦ រវ. ចច
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៦
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីសេរីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

LE MINISTÈRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៦/២៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក**

១-ឧត្តមសេនីយ៍ទោ **ពីន សេដ្ឋថុល** អត្តលេខ ០០០៥៩៥
២-ឧត្តមសេនីយ៍ទោ **នឹម មាលា** អត្តលេខ ០១៩៧៥៥

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី **សាយ សុវិន្ទ** អត្តលេខ ០០៤៦៥៧
២-ឧត្តមសេនីយ៍ត្រី **អ៊ុច មុន្នី** អត្តលេខ ០៦៧៩៥១
៣-ឧត្តមសេនីយ៍ត្រី **តាត់ សុភាព** អត្តលេខ ០០១៥៦០
៤-ឧត្តមសេនីយ៍ត្រី **ប្រុក សាម៉ុន** អត្តលេខ ០០១៥១៦
៥-ឧត្តមសេនីយ៍ត្រី **សោម សុធី** អត្តលេខ ០៣១៦១២
៦-ឧត្តមសេនីយ៍ត្រី **ហម សុធី** អត្តលេខ ០០១៥១៨
៧-ឧត្តមសេនីយ៍ត្រី **នរិន្ទ្រ រិទ្ធ** អត្តលេខ ១៩៨៧០២
៨-ឧត្តមសេនីយ៍ត្រី **ធន សុខេង** អត្តលេខ ០០១៤០៦
៩-ឧត្តមសេនីយ៍ត្រី **គង់ វណ្ណី** អត្តលេខ ០០១៤០៤
១០-ឧត្តមសេនីយ៍ត្រី **ខួន តារា** អត្តលេខ ០០៨៥៨៥
១១-ឧត្តមសេនីយ៍ត្រី **ឃឹម ថាវី** អត្តលេខ ០០១៤១០

**គ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **ខៀវ ចាន់នៅ** អត្តលេខ ០១៤១៩៩
២-វរសេនីយ៍ឯក **សួស ផានី** អត្តលេខ ០១៤១៩៣

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

| | | | |
|---|---|---|---|
| ៣-វរសេនីយ៍ឯក | **សំ** | **សុទ្ធារិទ្ធ** | អត្តលេខ ២១៩៦៨៤ |
| ៤-វរសេនីយ៍ឯក | **ហ៊ុល** | **ម៉ុនឡើត** | អត្តលេខ ០០១៣៨៥ |
| ៥-វរសេនីយ៍ឯក | **សៅ** | **ដារ៉ាឌុធ** | អត្តលេខ ០១៣៩៩៥ |
| ៦-វរសេនីយ៍ឯក | **សូ** | **សំណាង** | អត្តលេខ ០២៤៨៣៩ |
| ៧-វរសេនីយ៍ឯក | **អ៊ុត** | **សារ៉ាន** | អត្តលេខ ០៤៨១២៥ |
| ៨-វរសេនីយ៍ឯក | **ឆួយ** | **សុផល** | អត្តលេខ ០២៩៩៣១ |

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត/០៣១៦/២៧៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១៦*

**លេខៈ** ២៧៧ ស.ណ

**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៤៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១..**

ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ ទៅជា «វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ» ហៅកាត់ថា «វ.ព.ព» និងជាភាសាអង់គ្លេស «Polytechnic Institute of Preah Sihanouk» ហៅកាត់ថា «P.I.P»។ វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុនេះជាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសាធារណៈ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារនិងបណ្តុះណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅ ក្រុមទី១៥ ភូមិ២ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

**មាត្រា២..**

វ.ព.ព មានភារកិច្ចធ្វើការបណ្តុះបណ្តាល ៖

- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈសិក្សារយៈពេលខ្លីក្រោម១ ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ , ២ និង៣ សិក្សារយៈពេល ១ឆ្នាំ ឬ២ឆ្នាំ ឬ៣ឆ្នាំ ដែលមានយ៉ាងតិច ៣០ក្រេឌីត (សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឯកទេស បរិញ្ញាបត្ររងសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ដែលមានយ៉ាងតិច ៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា ឬឯកទេសសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ដែលមានយ៉ាងតិច ១២០ក្រេឌីត។

**មាត្រា៣..**

វ.ព.ព បណ្តុះបណ្តាលលើមុខជំនាញដូចខាងក្រោម ៖

- វិស្វកម្មអគ្គិសនីនិងវិស្វកម្មអេឡិចត្រូនិច
- វិស្វកម្មសំណង់ស៊ីវិល
- ព័ត៌មានវិទ្យា
- គ្រប់គ្រងពាណិជ្ជកម្ម
- សណ្ឋាគារនិងទេសចរណ៍
- ភាសាបរទេស។

នៅថ្ងៃអនាគត វិទ្យាស្ថាននេះអាចបើកជំនាញ ឬឯកទេសដទៃទៀតដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤.-**

លក្ខខណ្ឌទទួលសិស្ស-និស្សិតឲ្យចូលរៀន ៖

- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ បេក្ខជនជាសិក្ខាកាម សិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ បេក្ខជនបានរៀនចប់ថ្នាក់ទី៩ នៃមធ្យមសិក្សាបឋមភូមិ ឬវិញ្ញាបនបត្រស្ពានចម្លងបន្តជំនាញឬវិញ្ញាបនបត្រដែលមានតម្លៃស្មើ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២ បេក្ខជនដែលមានសញ្ញាបត្របច្ចេកទេស និងវិជ្ជា-ជីវៈ ១
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ៣ បេក្ខជនដែលមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ២
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឯកទេស បរិញ្ញាបត្ររង បេក្ខជនមានសញ្ញាបត្រមធ្យម-សិក្សា ទុតិយភូមិ( ជាប់ ឬធ្លាក់ )ឬមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា ឯកទេសសញ្ញាបត្រវិស្វករ បេក្ខជនមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស បរិញ្ញាបត្ររងឬសញ្ញាបត្រ ដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស-និស្សិតឲ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**មាត្រា៥.-**

**វ.ព.៣** ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍ និងការងារពាក់ព័ន្ធផ្សេងៗទៀតរបស់វិទ្យាស្ថាន។

**មាត្រា៦.-**

**វ.ព.៣** ត្រូវដឹកនាំដោយនាយកមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករងមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋាន តាមការចាំបាច់។

រចនាសម្ព័ន្ធរបស់ **វ.ព.៣** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៧.-**

សិស្ស-និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់ **វ.ព.៣** ហើយទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលបានវិញ្ញាបនបត្រឬសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬ

សញ្ញាបត្រដែលផ្តល់ឲ្យដោយ វ.ព.ព នឹងត្រូវទទួលស្គាល់ ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងករណី វ.ព.ព បានបំពេញនិងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៨.-**

មន្ត្រីដែលបម្រើការងារនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ ត្រូវនៅបំពេញភារកិច្ចតាមតួនាទីរបស់ខ្លួនរហូតដល់មានការតែងតាំងថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ២ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**

សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៥...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃនិយ័តករទូរគមនាគមន៍កម្ពុជា (**ន.ទ.ក.**) ។

## ជំពូកទី២
## មុខងារនិងភារកិច្ច និងរចនាសម្ព័ន្ធនៃនិយ័តករទូរគមនាគមន៍កម្ពុជា

**មាត្រា២ .-**

**ន.ទ.ក.** បំពេញមុខងារដោយមានស្វ័យភាពខាងផ្នែករដ្ឋបាលនិងនិយ័តកម្ម ព្រមទាំងដោយឯករាជ្យពីប្រតិបត្តិករទូរគមនាគមន៍និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ។

**មាត្រា៣ .-**

**ន.ទ.ក.** ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប ឋានៈស្មើរដ្ឋលេខាធិការ និងមានសមាជិកមួយចំនួនដែលមានឋានៈស្មើអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

ប្រធាននិងសមាជិក **ន.ទ.ក.** មានអាណត្តិ៣(បី)ឆ្នាំ ។ អាណត្តិនេះអាចបន្តសាជាថ្មី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) ជូនប្រមុខរាជរដ្ឋាភិបាល ។

សមាជិក **ន.ទ.ក.** មានមុខងារនិងបំពេញភារកិច្ចទាំងឡាយដែលប្រធាន **ន.ទ.ក.** ប្រគល់ឱ្យ លើកលែងតែមុខងារនិងភារកិច្ចដែលត្រូវបានកំណត់ក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ ។

## ផ្នែកទី១
## មុខងារនិងភារកិច្ចរបស់ប្រធាននិងសមាជិកនៃនិយ័តករទូរគមនាគមន៍កម្ពុជា

**មាត្រា៤ .-**

ប្រធាន **ន.ទ.ក.** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រងនិងអនុវត្តការងារដែលមានចែងក្នុងច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការធ្វើនិយ័តកម្មលើវិស័យទូរគមនាគមន៍ ។ ប្រធាន **ន.ទ.ក.** មានមុខងារនិងភារកិច្ចបន្ថែមដូចខាងក្រោម ៖

- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ **ន.ទ.ក.**
- ដឹកនាំការប្រជុំរបស់ **ន.ទ.ក.**
- រៀបចំយុទ្ធសាស្ត្រនិងផែនការការងារនៃការធ្វើនិយ័តកម្ម ដើម្បីចូលរួមអភិវឌ្ឍវិស័យទូរគមនាគមន៍ ជូនរដ្ឋមន្ត្រី **ក.ប.ទ.** ពិនិត្យនិងសម្រេច
- ចុះកិច្ចសន្យានិងអនុស្សរណៈផ្សេងៗក្នុងនាម **ក.ប.ទ.** ដោយមានការឯកភាពពីរដ្ឋមន្ត្រី **ក.ប.ទ.**
- ជាតំណាងរបស់ **ន.ទ.ក.** ក្នុងទំនាក់ទំនងជាមួយតតិយជន ដូចជាស្ថាប័នជាតិនិងអន្តរជាតិ ព្រមទាំងវិស័យឯកជននានា ដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការលើការធ្វើនិយ័តកម្មក្នុងវិស័យទូរគមនាគមន៍

- ជានាការផ្សព្វផ្សាយនិងអនុវត្តរាល់សេចក្តីសម្រេចរបស់ **ន.ទ.ក.**
- ជាតំណាងឱ្យ **ន.ទ.ក.** នៅចំពោះមុខតុលាការ
- គ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរបស់ **ន.ទ.ក.** ស្របតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន
- គ្រប់គ្រងមន្ត្រីនិងបុគ្គលិករបស់ **ន.ទ.ក.**
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យនិងសម្រេច និង
- អនុវត្តការងារផ្សេងទៀតទៅតាមការណែនាំរបស់រដ្ឋមន្ត្រី **ក.ប.ទ.** ។

**មាត្រា៥ .-**

ប្រធាន **ន.ទ.ក.** អាចមានអ្នកជំនាញការជាតិនិងអន្តរជាតិមួយចំនួនដែលមានសមត្ថភាពជំនាញនិងបទពិសោធន៍ខ្ពស់ ដើម្បីជួយបម្រើការងារជាទីប្រឹក្សាបច្ចេកទេស ។

**មាត្រា៦ .-**

សមាជិក **ន.ទ.ក.** មានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- ជាជំនួយការប្រធានក្នុងការសម្របសម្រួលដឹកនាំការងារនាយកដ្ឋាននានាចំណុះឱ្យ **ន.ទ.ក.** តាមការចាត់តាំងរបស់ប្រធាន **ន.ទ.ក.**
- ចូលរួមកិច្ចប្រជុំនានាតាមការកោះហៅរបស់ប្រធាន **ន.ទ.ក.**
- បំពេញតួនាទីជាប្រធានស្តីទីក្នុងករណីប្រធានប្រគល់សិទ្ធិ និង
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ប្រធាន **ន.ទ.ក.** ។

## **ផ្នែកទី២**
## **បេក្ខភាពរបស់ប្រធាននិងសមាជិកនៃនិយ័តករទូរគមនាគមន៍កម្ពុជា**

**មាត្រា៧ .-**

បុគ្គលដែលអាចត្រូវបានជ្រើសរើសជាប្រធាននិងសមាជិក **ន.ទ.ក.** ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុយ៉ាងតិច៣៥(សាមសិបប្រាំ)ឆ្នាំ គិតដល់ថ្ងៃតែងតាំង
- មានសញ្ញាបត្រថ្នាក់ឧត្តមសិក្សា និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ព្រមទាំងមានបទពិសោធយ៉ាងតិច១០(ដប់)ឆ្នាំ សម្រាប់ជំនាញមួយ ឬច្រើនដូចជាទូរគមនាគមន៍ ព័ត៌មានវិទ្យា នីតិសាស្ត្រ រដ្ឋបាលសាធារណៈ សេដ្ឋកិច្ច និងពាណិជ្ជកម្ម ឬផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្តែង
- មានសមត្ថភាពការងារ មានភាពស្អាតស្អំ និងមានគុណធម៌ និង
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយ ឬធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយ តែត្រូវបានទទួលនីតិសម្បទារួចហើយ ។

**មាត្រា៨ .–**

ក្នុងអាណត្តិរបស់ខ្លួន ប្រធាននិងសមាជិក **ន.ទ.ក.** មានវិសមិតភាពជាមួយសមាជិកក្រុមប្រឹក្សា-ធម្មនុញ្ញ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា ឬសមាជិករាជរដ្ឋាភិបាល ។

**មាត្រា៩ .–**

ប្រធាននិងសមាជិកព្រមទាំងមន្ត្រីទាំងអស់របស់ **ន.ទ.ក.** មិនអាចមានភាគហ៊ុនដោយផ្ទាល់ឬមានផលប្រយោជន៍សេដ្ឋកិច្ចឬមានមុខនាទីជាមួយប្រតិបត្តិករទូរគមនាគមន៍ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ឬអ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណបានឡើយ ប៉ុន្តែអាចធ្វើជាអ្នកជាវឬអ្នកប្រើប្រាស់សេវារបស់ប្រតិបត្តិករទូរគមនាគមន៍ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ។

ក្នុងអាណត្តិរបស់ខ្លួន ប្រធាននិងសមាជិកទាំងអស់របស់ **ន.ទ.ក.** ព្រមទាំងសហព័ទ្ធឬកូនមិនអាចចូលបម្រើការងារឬទទួលតំណែងណាមួយជាទីប្រឹក្សាឬជាអ្នកពិគ្រោះការងារ និងមិនអាចមានភាគហ៊ុនឬមានផលប្រយោជន៍ជាប្រាក់ជាមួយប្រតិបត្តិករទូរគមនាគមន៍ ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ណាមួយបានឡើយ ។

ប្រធានឬសមាជិក **ន.ទ.ក.** ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

**មាត្រា១០ .–**

តំណែងប្រធានឬសមាជិក **ន.ទ.ក.** ត្រូវចាត់ទុកថានៅទំនេរ នៅពេលដែលសាមីជន ៖

- ទទួលមរណភាព
- លាលែងពីមុខតំណែងជាលាយលក្ខណ៍អក្សរ
- ចូលនិវត្តន៍
- បាត់បង់សមត្ថភាពការងារខាងបញ្ញាស្មារតីនិងកាយសម្បទាដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច
- មានកំហុសធ្ងន់ធ្ងរនិងខ្វះការទទួលខុសត្រូវក្នុងការបំពេញភារកិច្ចរបស់ខ្លួន ឬ
- ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយ ។

**មាត្រា១១ .–**

ក្នុងករណីដែលតំណែងប្រធានឬសមាជិក **ន.ទ.ក.** នៅទំនេរមុនចប់អាណត្តិ រដ្ឋមន្ត្រី **ក.ប.ទ.** ត្រូវរៀបចំសមាសភាពថ្មីស្នើទៅប្រមុខរាជរដ្ឋាភិបាល ដើម្បីស្នើសុំតែងតាំងបំពេញអាណត្តិរបស់ប្រធានឬសមាជិកនៅទំនេរនោះ ។

ប្រធានឬសមាជិកជំនួស ត្រូវបំពេញមុខងារនិងភារកិច្ចរហូតដល់ចប់អាណត្តិដើមរបស់ប្រធានឬសមាជិកដែលត្រូវបានជំនួសនោះ ។

**មាត្រា១២ .–**

ក្នុងរយៈពេល២(ពីរ)ឆ្នាំចាប់ពីពេលបញ្ចប់អាណត្តិឬលាលែងពីមុខតំណែងរបស់ខ្លួន ប្រធាននិងសមាជិក **ន.ទ.ក.** មិនត្រូវបានអនុញ្ញាតឱ្យចូលបម្រើការងារ ឬមានទំនាក់ទំនងជាទីប្រឹក្សាឬជាអ្នកជំនាញការ

ឬជាអ្នកពិគ្រោះយោបល់ជូនប្រតិបត្តិករទូរគមនាគមន៍  ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ណាមួយបាន ឡើយ ។

**មាត្រា១៣ .-**

ប្រធាននិងសមាជិក **ន.ទ.ក.** ត្រូវរៀបចំកិច្ចប្រជុំពេញអង្គ ដើម្បីសម្រេចលើករណីណាមួយ ដូចខាងក្រោម ៖

- ការផ្តល់ ការកែប្រែ ការព្យួរ ឬការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ
- ការចេញសេចក្តីសម្រេចបន្ថែមលើករណីមួយចំនួនស្របតាមមាត្រា៥ ចំណុច(ច)នៃច្បាប់ស្តីពីទូរគមនា-គមន៍
- ផែនការអភិវឌ្ឍក្នុងការធ្វើនិយ័តកម្មលើវិស័យទូរគមនាគមន៍    ស្របតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន
- ការចាត់វិធានការទាំងឡាយស្របតាមមាត្រា៦៣ មាត្រា៦៩ និងមាត្រា១០២ នៃច្បាប់ស្តីពីទូរគមនា-គមន៍
- លទ្ធកម្មសាធារណៈស្របតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន
- ផែនការថវិកាប្រចាំឆ្នាំរបស់ **ន.ទ.ក.** ស្របតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន និង
- ការដោះស្រាយវិវាទ ។

ការកោះប្រជុំពេញអង្គនិងការអនុម័តសេចក្តីសម្រេចត្រូវបានធ្វើឡើងស្របនឹងបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា២៣ មាត្រា២៤ មាត្រា២៥ និងមាត្រា២៦ នៃអនុក្រឹត្យនេះ ។

## ផ្នែកទី៣
## រចនាសម្ព័ន្ធនៃនិយ័តករទូរគមនាគមន៍កម្ពុជា

**មាត្រា១៤ .-**

**ន.ទ.ក.** មានរចនាសម្ព័ន្ធដូចតទៅ ៖

- នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងទំនាក់ទំនងអន្តរជាតិ
- នាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ
- នាយកដ្ឋាននិយ័តកម្មទូរគមនាគមន៍
- នាយកដ្ឋាននិយ័តកម្មប្រេកង់វិទ្យុ
- នាយកដ្ឋានការប្រកួតប្រជែងនិងការការពារអ្នកប្រើប្រាស់
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង និង
- សាខារបស់ **ន.ទ.ក.** នៅតាមខេត្ត ។

នាយកដ្ឋាននីមួយៗ  ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន១(មួយ)រូប  និងមានអនុប្រធាននាយកដ្ឋានចំនួនច្រើនបំផុតពី៣(បី)រូបទៅ៥(ប្រាំ)រូប។  នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។      ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះរបស់នាយកដ្ឋាននីមួយៗត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**តាមសំណើរបស់ប្រធាន **ន.ទ.ក.** ។

អង្គការលេខរបស់ **ន.ទ.ក.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា១៥ .-**

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងទំនាក់ទំនងអន្តរជាតិ មានមុខងារនិងភារកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលរាល់ការងារទូទៅរបស់ **ន.ន.ក.**
- គ្រប់គ្រងនិងតាមដានរាល់ចរាចរនូវរាល់សំណុំលិខិតនិងឯកសាររដ្ឋបាលផ្សេងៗរបស់ **ន.ន.ក.**
- គ្រប់គ្រងសៀវភៅទទួលនិងបញ្ជូនសំណុំលិខិតឯកសារឱ្យបានត្រឹមត្រូវនិងច្បាស់លាស់
- គ្រប់គ្រងចរាចរឯកសារនិងលិខិតរដ្ឋបាលផ្សេងៗ ព្រមទាំងថែរក្សាឯកសារ និងផ្សព្វផ្សាយព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរ ប្រកាស សេចក្តីសម្រេចនិងឯកសារពាក់ព័ន្ធផ្សេងៗឱ្យមានសណ្តាប់ធ្នាប់និងមានសុវត្ថិភាព ព្រមទាំងផ្តល់ឯកសារជូនតាមសេចក្តីត្រូវការរបស់ថ្នាក់ដឹកនាំ
- រៀបចំសម្របសម្រួលនិងធ្វើកំណត់ត្រាកិច្ចប្រជុំរបស់ **ន.ន.ក.**
- រៀបចំសណ្តាប់ធ្នាប់ទូទៅ ការងារសន្តិសុខ និងសុវត្ថិភាពរបស់ **ន.ន.ក.**
- គ្រប់គ្រងទ្រព្យសម្បត្តិ សន្និធិសម្ភារៈ បញ្ជីសារពើភ័ណ្ឌ និងមធ្យោបាយដឹកជញ្ជូនរបស់ **ន.ន.ក.**
- ធានាប្រសិទ្ធភាពនិងសុវត្ថិភាពការងាររដ្ឋបាលនិងការងារសង្គមរបស់ **ន.ន.ក.**
- សិក្សា ស្រាវជ្រាវ និងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលរបស់ **ន.ន.ក.**
- តាក់តែងលិខិតរដ្ឋបាលនិងលិខិតស្នាមផ្សេងៗ
- គ្រប់គ្រងនិងផ្តល់សេវាបច្ចេកវិទ្យាព័ត៌មាន
- ផ្គត់ផ្គង់និងជួសជុលសម្ភារៈបរិក្ខារការិយាល័យ
- រៀបចំគម្រោងនិងត្រួតពិនិត្យការងារសាងសង់និងជួសជុលសំណង់គ្រប់ប្រភេទរបស់ **ន.ន.ក.**
- ចាត់ចែងការងារពិធីការ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋឬឯកជននានា
- គ្រប់គ្រងនិងអភិវឌ្ឍផែនការសមត្ថភាពរបស់មន្ត្រី **ន.ន.ក.** ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- បំពេញមុខងារជាចំណុចទាក់ទងរាល់កិច្ចការអន្តរជាតិ
- រៀបចំ ពិនិត្យ តាមដាន និងផ្តល់យោបល់លើរាល់ឯកសារដែលទាក់ទងនឹងការងារសហប្រតិបត្តិការអន្តរជាតិ
- រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីទាក់ទងនឹងនិយ័តកម្មលើវិស័យទូរគមនាគមន៍
- សិក្សានិងស្រាវជ្រាវឯកសារដែលទាក់ទងនឹងអង្គការអន្តរជាតិក្នុងវិស័យទូរគមនាគមន៍
- ចូលរួមរាល់សកម្មភាពការងារដែលទាក់ទងនឹងអង្គការអន្តរជាតិ
- រៀបចំនិងសហការជាមួយអង្គភាពពាក់ព័ន្ធសម្រាប់កិច្ចប្រជុំអន្តរជាតិក្នុងប្រទេស
- បូកសរុបរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ **ន.ន.ក.**
- រៀបចំផែនការសកម្មភាពនិងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន **ន.ន.ក.** ។

**មាត្រា១៦ .-**

នាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ មានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- រៀបចំផែនការអភិវឌ្ឍ ផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំរបស់ **ន.ទ.ក.**
- គ្រប់គ្រងបេឡា
- តាមដាននិងសម្របសម្រួលការគ្រប់គ្រងថវិកាស្របតាមនីតិវិធីហិរញ្ញវត្ថុនិងបទប្បញ្ញត្តិជាធរមាន
- រៀបចំស្នើសុំគោលការណ៍ផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនប្រធាន សមាជិក មន្ត្រី និងបុគ្គលិករបស់ **ន.ទ.ក.**
- គ្រប់គ្រង កត់ត្រា តាមដាន និងតឹងទារបំណុល
- គ្រប់គ្រងបញ្ជិកាគណនេយ្យរបស់ **ន.ទ.ក.**
- រៀបចំលើកសំណើសុំគោលការណ៍ជានាចំណាយនិងការទូទាត់
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ **ន.ទ.ក.**
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន **ន.ទ.ក.** ។

**មាត្រា១៧ .-**

នាយកដ្ឋាននិយ័តកម្មទូរគមនាគមន៍ មានមុខងារនិងភារកិច្ច ដូចខាងក្រោម ៖

- ធ្វើនិយ័តកម្មពាក់ព័ន្ធនឹងការតភ្ជាប់បណ្តាញរវាងប្រតិបត្តិករនិងប្រតិបត្តិករ ការកំណត់ស្តង់ដាសម្រាប់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញនិងការផ្តល់សេវាទូរគមនាគមន៍ និងស្តង់ដាគ្រឿងសម្ភារៈបរិក្ខារគមនាគមន៍ ព្រមទាំងប្លង់លេខទូរគមនាគមន៍ជាតិនិងអាសយដ្ឋានអេឡិកត្រូនិក ស្របតាមគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តនៃវិស័យទូរគមនាគមន៍ និងបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិការដូចបានកំណត់ក្នុងចំណុចទីមួយនៃមាត្រានេះ
- ទទួល ពិនិត្យ សិក្សា វិភាគ វាយតម្លៃ តាមដាន និងសម្របសម្រួលលើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ
- ផ្តល់សេវាប្រឹក្សាយោបល់ទាក់ទងនឹងការចុះបញ្ជីនិងផ្តល់ព័ត៌មានពាក់ព័ន្ធ
- ផ្តល់សេចក្តីសន្និដ្ឋាននិងអនុសាសន៍ជូន **ន.ទ.ក.** លើសំណុំឯកសារស្នើសុំលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ
- ផ្តល់ កែប្រែ ព្យួរ ផ្ទេរ ឬដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណស្របតាមការសម្រេចរបស់ **ន.ទ.ក.**
- រៀបចំនិងផ្សព្វផ្សាយសេចក្តីសម្រេចពាក់ព័ន្ធនឹងការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរឬការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ
- បង្កើតនិងរក្សាបញ្ជីលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ ព្រមទាំងកិច្ចព្រមព្រៀងស្តីពីការតភ្ជាប់និងកិច្ចព្រមព្រៀងគោល

- ប្រមូល ពិនិត្យ តាមដាន សិក្សា វិភាគ និងវាយតម្លៃលើនិយ័តកម្មពាក់ព័ន្ធនឹងប្រតិបត្តិការដូចបានកំណត់ក្នុងចំណុចទីមួយនៃមាត្រានេះ នៅថ្នាក់តំបន់និងពិភពលោក
- រៀបចំសេចក្តីណែនាំបន្ថែមពាក់ព័ន្ធនឹងប្រតិបត្តិការដូចបានកំណត់ក្នុងចំណុចទីមួយនៃមាត្រានេះ ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិផ្សេងទៀត ជូន **ន.ទ.ក.**
- ពិនិត្យនិងលើកសំណើធ្វើវិសោធនកម្មប្រកាសឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងប្រតិបត្តិការដូចបានកំណត់ក្នុងចំណុចទីមួយនៃមាត្រានេះ ជូន **ន.ទ.ក.**
- ប្រមូល សិក្សា វិភាគ តាមដាន និងគ្រប់គ្រងស្ថិតិពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- សហការផ្សព្វផ្សាយរបាយការណ៍ស្ថិតិពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- សហការរៀបចំក្រមសីលធម៌វិជ្ជាជីវៈនៃវិស័យទូរគមនាគមន៍
- សហការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ និងលក្ខខណ្ឌទាំងឡាយនៃប្រតិបត្តិការដូចបានកំណត់ក្នុងចំណុចទីមួយនៃមាត្រានេះ
- សហការណែនាំនិងផ្សព្វផ្សាយអំពីស្តង់ដានៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ប្លង់លេខទូរគមនាគមន៍និងអាសយដ្ឋានអេឡិកត្រូនិក ស្របតាមការណែនាំរបស់ **ក.ប.ទ.**
- រាយការណ៍អំពីលទ្ធផលនៃការស្រាវជ្រាវ ការស៊ើបអង្កេត និងការបង្ក្រាបអំពើល្មើស ជូន **ន.ទ.ក.**
- ស្នើសុំចាត់វិធានការនានាពាក់ព័ន្ធនឹងការបំពានលើការអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិផ្សេងទៀតជូន **ន.ទ.ក.**
- រៀបចំផែនការសកម្មភាពនិងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ៩ខែ និងប្រចាំឆ្នាំ និង
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន **ន.ទ.ក.** ។

**មាត្រា១៨ .-**

នាយកដ្ឋាននិយ័តកម្មប្រេកង់វិទ្យុ មានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- ធ្វើនិយ័តកម្មពាក់ព័ន្ធនឹងការប្រើប្រាស់ប្រេកង់វិទ្យុ និងការអនុវត្តលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងការចុះបញ្ជីប្រើប្រាស់ប្រេកង់វិទ្យុឬអាជ្ញាបណ្ណប្រេកង់វិទ្យុ ស្របតាមគោលនយោបាយនិងក្របខ័ណ្ឌគតិយុត្តនៃវិសាលគមន៍ប្រេកង់វិទ្យុនិងបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រេកង់វិទ្យុ និងលក្ខខណ្ឌនៃការចុះបញ្ជីប្រើប្រាស់ប្រេកង់វិទ្យុនិងអាជ្ញាបណ្ណប្រេកង់វិទ្យុ
- ទទួល ពិនិត្យ សិក្សា វិភាគ វាយតម្លៃ តាមដាន និងសម្របសម្រួលលើសំណុំឯកសារស្នើសុំការចុះបញ្ជីប្រើប្រាស់ប្រេកង់វិទ្យុ និងអាជ្ញាបណ្ណប្រេកង់វិទ្យុ
- ផ្តល់សេវាប្រឹក្សាយោបល់ទាក់ទងនឹងការចុះបញ្ជីនិងផ្តល់ព័ត៌មានពាក់ព័ន្ធ
- ផ្តល់សេចក្តីសន្និដ្ឋាននិងអនុសាសន៍ជូន **ន.ទ.ក.** លើសំណុំឯកសារស្នើសុំអាជ្ញាបណ្ណប្រេកង់វិទ្យុ
- ផ្តល់ កែប្រែ ព្យួរ ឬដកហូតអាជ្ញាបណ្ណប្រេកង់វិទ្យុស្របតាមការសម្រេចរបស់ **ន.ទ.ក.**
- រៀបចំនិងផ្សព្វផ្សាយសេចក្តីសម្រេចនានាពាក់ព័ន្ធនឹងការផ្តល់ ការកែប្រែ ការព្យួរ ឬការដកហូតអាជ្ញាបណ្ណប្រេកង់វិទ្យុ

- ចុះបញ្ជីការប្រើប្រាស់ហ្វ្រេកង់សិវិទ្យុ
- បង្កើតនិងរក្សាបញ្ជីនៃការប្រើប្រាស់ហ្វ្រេកង់សិវិទ្យុ និងអាជ្ញាបណ្ណហ្វ្រេកង់សិវិទ្យុ
- ប្រមូល ពិនិត្យ តាមដាន សិក្សា វិភាគ និងវាយតម្លៃលើនិយ័តកម្មពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការប្រើប្រាស់ហ្វ្រេកង់សិវិទ្យុ នៅថ្នាក់តំបន់និងពិភពលោក
- រៀបចំសេចក្តីណែនាំបន្ថែមពាក់ព័ន្ធនឹងការប្រើប្រាស់ហ្វ្រេកង់សិវិទ្យុស្របតាមច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិផ្សេងទៀត ជូន **ន.ឆ.ក.**
- ពិនិត្យនិងលើកសំណើធ្វើវិសោធនកម្មលើផែនការជាតិ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងហ្វ្រេកង់សិវិទ្យុ ជូន **ន.ឆ.ក.**
- រៀបចំឯកសារចូលទាំងឡាយពាក់ព័ន្ធនឹងហ្វ្រេកង់សិវិទ្យុជូនទៅ **ក.ប.ឆ.** ដើម្បីរៀបចំការចុះបញ្ជីគោលហ្វ្រេកង់សិវិទ្យុអន្តរជាតិ (Master International Frequency Register) នៅសហភាពទូរគមនាគមន៍អន្តរជាតិ
- សហការសម្របសម្រួលការងារជាមួយបណ្តាអង្គភាពហ្វ្រេកង់សិវិទ្យុនៃប្រទេសជាប់ព្រំដែនលើនិយ័តកម្មនៃវិសាលគមន៍ហ្វ្រេកង់សិវិទ្យុ ក្រោមការដឹកនាំរបស់ **ក.ប.ឆ.**
- គ្រប់គ្រង ថែទាំ និងប្រើប្រាស់ឧបករណ៍និងបរិក្ខាររបស់ **ន.ឆ.ក.** ដើម្បីត្រួតពិនិត្យនិងតាមដានការប្រើប្រាស់ហ្វ្រេកង់សិវិទ្យុ
- ប្រមូល សិក្សា វិភាគ តាមដាន និងគ្រប់គ្រងស្ថិតិពាក់ព័ន្ធនឹងហ្វ្រេកង់សិវិទ្យុ
- សហការផ្សព្វផ្សាយរបាយការណ៍ស្ថិតិពាក់ព័ន្ធនឹងហ្វ្រេកង់សិវិទ្យុ
- សហការណែនាំនិងផ្សព្វផ្សាយអំពីស្តង់ដាវិទ្យុគមនាគមន៍ ស្របតាមការណែនាំរបស់ **ក.ប.ឆ.**
- សហការត្រួតពិនិត្យទីតាំងស្ថានីយ៍វិទ្យុគមនាគមន៍ ស្របតាមការណែនាំរបស់ **ក.ប.ឆ.**
- សហការរៀបចំក្រមសីលធម៌វិជ្ជាជីវៈនៃវិស័យទូរគមនាគមន៍
- សហការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ និងលក្ខខណ្ឌទាំងឡាយនៃការប្រើប្រាស់ហ្វ្រេកង់សិវិទ្យុ
- រាយការណ៍អំពីលទ្ធផលនៃការស្រាវជ្រាវ ការស៊ើបអង្កេត និងការបង្ក្រាបអំពើល្មើស ជូន **ន.ឆ.ក.**
- ស្នើសុំចាត់វិធានការនានាពាក់ព័ន្ធនឹងការបំពានលើការអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិផ្សេងទៀតជូន **ន.ឆ.ក.**
- រៀបចំផែនការសកម្មភាពនិងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ៩ខែ និងប្រចាំឆ្នាំ និង
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន **ន.ឆ.ក.** ។

**មាត្រា១៩ .-**

នាយកដ្ឋានការប្រកួតប្រជែងនិងការការពារអ្នកប្រើប្រាស់ មានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពប្រកួតប្រជែងស្របច្បាប់និងស្មោះត្រង់ក្នុងទីផ្សារទូរគមនាគមន៍ ហើយត្រូវរាយការណ៍ជូន **ក.ប.ឆ.** ដើម្បីរៀបចំបទប្បញ្ញត្តិបន្ថែម
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តសិទ្ធិរបស់ប្រតិបត្តិករនិងអ្នកប្រើប្រាស់ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិជាធរមានផ្សេងទៀត

- ត្រួតពិនិត្យឯកសារផ្តល់ព័ត៌មានអំពីការគ្រប់គ្រងថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចដោយសវនករឯករាជ្យដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងព័ត៌មានពុំមែនហិរញ្ញវត្ថុដែលត្រូវផ្តល់ជូនដោយប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍រៀងរាល់ឆ្នាំសារពើពន្ធ
- ត្រួតពិនិត្យ សិក្សា និងវិភាគលើកិច្ចព្រមព្រៀងស្តីពីការផ្ទេរកិច្ចសន្យាឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញយកក្រុមហ៊ុនឬភាគហ៊ុន ឬការដាក់ប្រាតិភោគពាក់ព័ន្ធនឹងប្រតិបត្តិការទូរគមនាគមន៍
- ត្រួតពិនិត្យ សិក្សា និងវិភាគលើសន្តតិកម្មពាក់ព័ន្ធនឹងប្រតិបត្តិការទូរគមនាគមន៍និងលើសកម្មភាពទាំងឡាយណាដែលឈានទៅរកអរសោធនីយរបស់ប្រតិបត្តិករទូរគមនាគមន៍ឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគនាគមន៍
- ពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រកួតប្រជែងនិងការការពារអ្នកប្រើប្រាស់
- រៀបចំសេចក្តីណែនាំបន្ថែមពាក់ព័ន្ធនឹងការប្រកួតប្រជែងនិងការការពារអ្នកប្រើប្រាស់ ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិផ្សេងទៀត ជូន **ន.ទ.ក.**
- ពិនិត្យនិងលើកសំណើធ្វើវិសោធនកម្មប្រកាសឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រកួតប្រជែងនិងការការពារអ្នកប្រើប្រាស់ ជូន **ន.ទ.ក.**
- សហការណែនាំនិងផ្សព្វផ្សាយអំពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រកួតប្រជែងនិងការការពារអ្នកប្រើប្រាស់
- សហការរៀបចំក្រមសីលធម៌វិជ្ជាជីវៈនៃវិស័យទូរគមនាគមន៍
- ទទួលពាក្យបណ្តឹងនិងសហការស៊ើបអង្កេតអំពីប្រតិបត្តិការទាំងឡាយណាដែលឈានទៅដល់ការចាត់ទុកជាអំពើមិនប្រក្រតីឬអំពើល្មើស ផ្អែកតាមច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិផ្សេងទៀត
- ត្រួតពិនិត្យនិងដោះស្រាយវិវាទពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍និងបទប្បញ្ញត្តិផ្សេងទៀត
- សហការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបអាជីវកម្មខុសច្បាប់ ផ្ទុយនឹងក្រមសីលធម៌ លក្ខខណ្ឌនៃបច្ចេកវិទ្យា លក្ខខណ្ឌនៃស្តង់ដា គុណភាពនៃសេវា និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍
- រាយការណ៍ជាបន្ទាន់ជូន **ន.ទ.ក.** អំពីសកម្មភាពទាំងឡាយដែលឈានទៅរកការរំលោភបំពានលើគោលការណ៍ប្រកួតប្រជែងនិងសិទ្ធិរបស់អ្នកប្រើប្រាស់
- សហការពិនិត្យនិងផ្តល់យោបល់ ដើម្បីចាត់វិធានការដាក់វិន័យពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- រៀបចំផែនការសកម្មភាពនិងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ៩ខែ និងប្រចាំឆ្នាំ និង
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន **ន.ទ.ក.** ។

**មាត្រា២០ .-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ **ន.ទ.ក.** មានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- ធ្វើសវនកម្មលើអនុលោមភាព ការគ្រប់គ្រង និងហិរញ្ញវត្ថុរបស់ **ន.ទ.ក.** ស្របតាមផែនការសវនកម្មផ្ទៃក្នុង និងតាមការណែនាំរបស់រដ្ឋមន្ត្រី **ក.ប.ទ.**
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន **ន.ទ.ក.** ពិនិត្យនិងសម្រេច

- ធ្វើរបាយការណ៍ អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើជូនប្រធាន **ន.ឆ.ក.** ពិនិត្យនិងផ្តល់ការណែនាំ និង
- អនុវត្តការងារផ្សេងៗទៀត ដូចមានចែងក្នុងអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី **ក.ប.ឆ.** ។

## ជំពូកទី៣
## មន្ត្រីរបស់និយ័តករទូរគមនាគមន៍កម្ពុជា

**មាត្រា២១ .-**

បុគ្គលិកអចិន្ត្រៃយ៍របស់ **ន.ឆ.ក.** គឺជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានតែងតាំងឱ្យបម្រើការងារនៅក្នុង **ន.ឆ.ក.** ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ន.ឆ.ក.** អាចត្រូវបានអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលិករបស់ **ន.ឆ.ក.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុង ដែលសម្រេចដោយ **ន.ឆ.ក.**។

ចំពោះមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ បទបញ្ជាផ្ទៃក្នុងស្តីពីបុគ្គលិក ត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត របស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ។

មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបំពេញភារកិច្ចនៅ **ន.ឆ.ក.** ទទួលបានការផ្តល់លាភការប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ពីថវិការដ្ឋស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗក្រៅពីថវិការដ្ឋ ជូនបុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកជាប់កិច្ចសន្យានៃ **ន.ឆ.ក.** ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រី **ក.ប.ឆ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ប្រធាន **ន.ឆ.ក.**។

**មាត្រា២២ .-**

ប្រធាន **ន.ឆ.ក.** អាចជ្រើសរើសមន្ត្រីដែលមិនស្ថិតក្នុងក្របខ័ណ្ឌមុខងារសាធារណៈឬបុគ្គលិកជាប់កិច្ចសន្យា ដើម្បីយកទៅបម្រើការងារនៅ **ន.ឆ.ក.** ដោយផ្អែកទៅលើតម្រូវការចាំបាច់ និងស្របតាមបទប្បញ្ញត្តិជាធរមាន ។ មន្ត្រីទាំងនេះត្រូវគ្រប់គ្រងដោយលក្ខន្តិកៈរបស់ **ន.ឆ.ក.** ។

## ជំពូកទី៤
## ដំណើរការរបស់និយ័តករទូរគមនាគមន៍កម្ពុជា

**មាត្រា២៣ .-**

ប្រធាននិងសមាជិក **ន.ឆ.ក.** ត្រូវធ្វើការពេញម៉ោង។

ប្រធានឬសមាជិក **ន.ឆ.ក.** ចំនួនយ៉ាងតិច២(ពីរ)រូប មានសិទ្ធិស្នើសុំកិច្ចប្រជុំពេញអង្គ ។

ការប្រជុំពេញអង្គរបស់ **ន.ឆ.ក.** អាចធ្វើទៅបានលុះត្រាតែមានកូរ៉ុមចំនួន២/៣(ពីរភាគបី)នៃសមាជិក។

ការប្រជុំពេញអង្គត្រូវធ្វើឡើងក្រោមអធិបតីភាពរបស់ប្រធានឬប្រធានស្តីទី **ន.ឧ.ភ.** ។

**មាត្រា២៤ .-**

រាល់កិច្ចប្រជុំពេញអង្គត្រូវធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន **ន.ឧ.ភ.** ដោយបញ្ជាក់អំពីទីកន្លែង កាលបរិច្ឆេទ និងកម្មវត្ថុនៃកិច្ចប្រជុំពេញអង្គ និងដោយភ្ជាប់មកជាមួយនូវរបៀបវារៈ ព្រមទាំងត្រូវជូនដំណឹង យ៉ាងតិចចំនួន៣(បី)ថ្ងៃ មុនថ្ងៃប្រជុំពេញអង្គ លើកលែងតែមានករណីបន្ទាន់ ។

**មាត្រា២៥ .-**

ប្រធាននិងសមាជិក ត្រូវមានសំឡេងក្នុងការបោះឆ្នោតលើរាល់បញ្ហាដែលតម្រូវឱ្យមានការអនុម័តពី **ន.ឧ.ភ.** ។ ការអនុម័តនេះត្រូវផ្អែកលើសំឡេងភាគច្រើន ។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងប្រធានមាន ឧត្តមានុភាព។ ការអនុម័តរបស់ **ន.ឧ.ភ.** យកជាការបានលុះត្រាតែមានវត្តមានប្រធានឬប្រធានស្តីទី ។

សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកចូលរួមប្រជុំពេញអង្គជំនួសបានឡើយ ។

រាល់សេចក្តីសម្រេចរបស់ **ន.ឧ.ភ.** ត្រូវកត់ត្រាទុកជាកំណត់ហេតុនិងរបាយការណ៍នៃការប្រជុំ ពេញអង្គដោយមានចុះហត្ថលេខារបស់ប្រធាន សមាជិកទាំងអស់ដែលបានចូលរួមប្រជុំពេញអង្គ និង លេខាធិការនៃអង្គប្រជុំដែលត្រូវចាត់តាំងដោយប្រធាន ។

លេខាធិការនៃអង្គប្រជុំពុំមានសិទ្ធិបោះឆ្នោតឡើយ ។

**មាត្រា២៦ .-**

ដើម្បីធ្វើសេចក្តីសម្រេចណាមួយ ប្រធាននិងសមាជិក **ន.ឧ.ភ.** ត្រូវធ្វើការពិចារណាឱ្យបានហ្មត់ចត់ និងត្រឹមត្រូវលើបញ្ហាទាំងអស់ដែលពាក់ព័ន្ធឱ្យស្របទៅតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៧ .-**

មុនពេលប្រកាសដាក់ឱ្យប្រើសេចក្តីសម្រេចណាមួយរបស់ខ្លួន **ន.ឧ.ភ.** ត្រូវជូនដំណឹងពីខ្លឹមសារនិង លក្ខខណ្ឌ ហើយត្រូវផ្តល់ឱកាសឱ្យបុគ្គលដែលពាក់ព័ន្ធបង្ហាញភស្តុតាងនិងបញ្ចេញមតិយោបល់ ។ **ន.ឧ.ភ.** ត្រូវជូនដំណឹងក្នុងរយៈពេលមួយសមស្រប អំពីពេលវេលានិងទីកន្លែងសម្រាប់បុគ្គលនោះមានឱកាសផ្តល់ ភស្តុតាងនិងបញ្ចេញមតិយោបល់ ។

**មាត្រា២៨ .-**

បន្ទាប់ពី **ន.ឧ.ភ.** ចេញសេចក្តីសម្រេចជាចុងក្រោយ បុគ្គលពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាទៅតុលាការ មានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។ ការប្តឹងតវ៉ានេះត្រូវអនុវត្តក្នុងរយៈពេល៩០(កៅសិប)ថ្ងៃបន្ទាប់ពីថ្ងៃ ចេញសេចក្តីសម្រេច ។

**មាត្រា២៩ .-**

**ន.ឧ.ភ.** មាននិមិត្តសញ្ញានិងត្រាដោយឡែករបស់ខ្លួន ។

## ជំពូកទី៥
## ទម្រង់បែបបទនៃបញ្ជីលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ

**មាត្រា៣០ .-**

**ន.ទ.ភ** ត្រូវរៀបចំបញ្ជីនៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ ដោយរៀបចំចំណាត់ថ្នាក់ផ្អែកទៅតាមចរិតលក្ខណៈមួយចំនួនជាអាទិ៍ ប្រភេទនៃប្រតិបត្តិការ រយៈពេល កាលបរិច្ឆេទនៃការចុះបញ្ជី និងអត្តសញ្ញាណរូបវន្តបុគ្គលឬនីតិបុគ្គល លក្ខខណ្ឌបច្ចេកទេសនៃការទទួលសិទ្ធិប្រើប្រាស់និងអាជីវកម្ម ព្រមទាំងបញ្ជីឧបសម្ព័ន្ធជាអាទិ៍ ផែនការវិនិយោគ ផែនការអាជីវកម្មនិងផែនការហិរញ្ញវត្ថុ ។

## ជំពូកទី៦
## ប្រភពធនធាន

**មាត្រា៣១ .-**

ប្រភពធនធានរបស់ **ន.ទ.ភ.** រួមមាន ៖

- ធនធានដែលរដ្ឋផ្តល់ឱ្យ **ន.ទ.ភ.** និង
- ធនធានដែល **ន.ទ.ភ.** រកបានដោយខ្លួនឯង។

ក្រៅពីប្រភពធនធានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ **ន.ទ.ភ.** ក៏មានប្រភពធនធានផ្សេងទៀតស្របតាមការកំណត់របស់ **ក.ប.ទ.** ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៣២ .-**

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន រចនាសម្ព័ន្ធបញ្ញត្តិករទូរគមនាគមន៍កម្ពុជានឹងត្រូវជំនួសដោយរចនាសម្ព័ន្ធដែលមានចែងក្នុងអនុក្រឹត្យនេះ ។

**មាត្រា៣៣ .-**

បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន **ន.ទ.ភ.** មានសិទ្ធិប្រើប្រាស់ថវិកាសម្រាប់ឆ្នាំ២០១៦ និងតុល្យការបន្តពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៣៤ .-**

អនុក្រឹត្យលេខ១៤០អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធាននិងសមាជិក **ន.ទ.ក.** ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ប្រាក់ សុខុន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់អនុក្រឹត្យលេខ..៤៥....អនក្រ.បក ចុះថ្ងៃទី..១៦.....ខែ..មីនា..ឆ្នាំ ២០១៦

## អង្គការលេខរបស់និយ័តករទូរគមនាគមន៍កម្ពុជា



# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤០៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ដាក់មន្ត្រីរាជការចំនួន ៧២ រូប របស់ក្រសួង ស្ថាប័នចំនួន ១៨ ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដូចមានរាយនាម និងថ្ងៃខែឆ្នាំចូលនិវត្តន៍ខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃខែឆ្នាំ ចូលនិវត្តន៍ |
|---|---|---|---|
| **១-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | |
| ១ | លោក សួន កំសាន្ត | វរមន្ត្រី ថ្នាក់លេខ ៤ | ១២/០២/២០១៦ |
| **២-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** | | | |
| ២ | លោក ឌិន ចន្ថា | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ | ០៩/០២/២០១៦ |
| **៣-ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ** | | | |
| ៣ | លោក ស្លូង សិរី | វរមន្ត្រី ថ្នាក់លេខ ២ | ២៨/០២/២០១៦ |

| | | | |
|---|---|---|---|
| ៤ | លោក ប្រាក់ ប៊ិន | វរមន្ត្រី ថ្នាក់លេខ ១ | ១៧/០៤/២០១៦ |
| **៤-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | | | |
| ៥ | លោក សុខ កែវ | វរមន្ត្រី ថ្នាក់លេខ ២ | ០២/០២/២០១៦ |
| ៦ | លោក ប៊ី សុផាត | វរមន្ត្រី ថ្នាក់លេខ ៤ | ០១/០២/២០១៦ |
| ៧ | លោក ទេព វិសិដ្ឋ | វរមន្ត្រី ថ្នាក់លេខ ២ | ០៩/០៤/២០១៦ |
| **៥-ក្រសួងអប់រំ យុវជន និង កីឡា** | | | |
| ៨ | លោកស្រី ឡាយ សុវណ្ណនី | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ១២/០២/២០១៦ |
| ៩ | លោក សេក សុខា | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ១៧/០២/២០១៦ |
| ១០ | លោកស្រី អ៊ឹម សុភាព | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ២៣/០២/២០១៦ |
| ១១ | លោក យិន សាបាន | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | ២១/០២/២០១៦ |
| ១២ | លោក ទូ ថាច | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | ០៥/០២/២០១៦ |
| ១៣ | លោក ប៊ុយ ប៊ុគឌីសែន | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | ១៥/០២/២០១៦ |
| ១៤ | លោក ឯក វណ្ណសាធ | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ១២/០៣/២០១៦ |
| ១៥ | លោក មាស ឡាំ | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ១៣/០៣/២០១៦ |
| ១៦ | លោក នព្វ ខេម | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ១១/០៣/២០១៦ |
| ១៧ | លោក កង ផៃ | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | ១១/០៣/២០១៦ |
| ១៨ | លោកស្រី សំ បុណ្ណា | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ២៦/០៤/២០១៦ |
| ១៩ | លោក កែវ សារ៉េត | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | ២៨/០៤/២០១៦ |
| ២០ | លោកស្រី អ៊ុក អដ្ឋវី | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | ១៧/០៤/២០១៦ |
| ២១ | លោក វ៉ា មឿន | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៤ | ១៣/០៤/២០១៦ |
| **៦-ក្រសួងបរិស្ថាន** | | | |
| ២២ | លោក គង់ សុផល | វរមន្ត្រី ថ្នាក់លេខ ២ | ០៥/០២/២០១៦ |
| ២៣ | លោក ជៀក អាង | វរមន្ត្រី ថ្នាក់លេខ ២ | ០២/០២/២០១៦ |
| ២៤ | លោក សំ ធា | វរមន្ត្រី ថ្នាក់លេខ ១ | ០៥/០៣/២០១៦ |
| **៧-ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ** | | | |
| ២៥ | លោក ថៅ ប៊ុនថា | វរមន្ត្រីការបរទេស ថ្នាក់លេខ ១ | ១៣/០៤/២០១៦ |

| | | | |
|---|---|---|---|
| **៨-ក្រសួងសុខាភិបាល** | | | |
| ២៦ | លោក អ៊ុយ បូរ៉ានី | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | ០៥/០២/២០១៦ |
| ២៧ | លោក ជេត ធីរ៉ា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ | ០៦/០២/២០១៦ |
| ២៨ | លោក ញ៉េប ណេត | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ | ០៧/០២/២០១៦ |
| ២៩ | លោកស្រី ខោល ខេមរារី | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | ០៦/០៣/២០១៦ |
| ៣០ | លោក ង៉ោ ស៊ិតធី | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | ០៧/០៣/២០១៦ |
| ៣១ | លោក ធីវ ជិនបាណ្ឌូល | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ | ០៣/០៣/២០១៦ |
| ៣២ | លោក អ៊ិត សំអុល | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ | ១០/០៣/២០១៦ |
| ៣៣ | លោក ប្រាក់ សុខហេង | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ | ១១/០៣/២០១៦ |
| ៣៤ | លោក ម៉ៅ ហេង | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ | ០២/០៣/២០១៦ |
| ៣៥ | លោក ជូ សឹត | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ | ៣០/០៣/២០១៦ |
| ៣៦ | លោក កែវ សុគន្ធ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ | ២០/០៤/២០១៦ |
| ៣៧ | លោក យឹម សម្បត្តិ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ | ២៦/០៤/២០១៦ |
| ៣៨ | លោកស្រី ប៉ុល សិរីមេធី | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | ០៤/០៤/២០១៦ |
| ៣៩ | លោក អ៊ឹង សុខុម | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | ២៧/០៤/២០១៦ |
| ៤០ | លោក ខៀវ សម្រស់ | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | ២៥/០៤/២០១៦ |
| ៤១ | លោកស្រី មឿង តារា | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ | ០៥/០៤/២០១៦ |
| **៩-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម** | | | |
| ៤២ | លោក ហែម សុភូ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ | ១២/០៣/២០១៦ |
| ៤៣ | លោក ឌុច ចំរ៉ាត់ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ | ២៦/០៤/២០១៦ |
| **១០-ក្រសួងព័ត៌មាន** | | | |
| ៤៤ | លោក ស្រី កុសល | វរមន្ត្រី ថ្នាក់លេខ ៣ | ១២/០៣/២០១៦ |
| ៤៥ | លោកស្រី អ៊ុម ប៊ុណ្ណា | វរមន្ត្រី ថ្នាក់លេខ ៤ | ១៥/០៤/២០១៦ |
| **១១-ក្រសួងមហាផ្ទៃ** | | | |
| ៤៦ | លោក អេង វណ្ណា | វរមន្ត្រី ថ្នាក់លេខ ១ | ០១/០២/២០១៦ |
| ៤៧ | លោក មាន់ អ៊ានលី | វរមន្ត្រី ថ្នាក់លេខ ១ | ០១/០២/២០១៦ |
| ៤៨ | លោក ខៀវ សុខណាត | វរមន្ត្រី ថ្នាក់លេខ ១ | ១៥/០២/២០១៦ |

| | | | |
|---|---|---|---|
| ៤៩ | លោក សុត សុង | វរមន្ត្រី ថ្នាក់លេខ ២ | ២០/០២/២០១៦ |
| ៥០ | លោក ឥម សោភ័ណរត្ន | វរមន្ត្រី ថ្នាក់លេខ ៣ | ២៥/០២/២០១៦ |
| ៥១ | លោក ឆាត់ សួន | វរមន្ត្រី ថ្នាក់លេខ ៣ | ០៥/០២/២០១៦ |
| ៥២ | លោក ពិន ខន | វរមន្ត្រី ថ្នាក់លេខ ១ | ១៥/០៣/២០១៦ |
| ៥៣ | លោក អ៊ឹម ថន | វរមន្ត្រី ថ្នាក់លេខ ២ | ១៥/០៣/២០១៦ |
| ៥៤ | លោកជំទាវ មឿង ស៊ាងសេង | វរមន្ត្រី ថ្នាក់លេខ ១ | ១៧/០៤/២០១៦ |
| ៥៥ | លោក សួន ញ៉ាក | វរមន្ត្រី ថ្នាក់លេខ ១ | ២០/០៤/២០១៦ |
| ៥៦ | លោក ឃឹម យោន | វរមន្ត្រី ថ្នាក់លេខ ១ | ០៧/០៤/២០១៦ |
| ៥៧ | លោក ខែក ផា | វរមន្ត្រី ថ្នាក់លេខ ១ | ០៣/០៤/២០១៦ |
| ៥៨ | លោក ផុន ផែន | វរមន្ត្រី ថ្នាក់លេខ ១ | ១៣/០៤/២០១៦ |
| ៥៩ | លោក ជាម ហេង | វរមន្ត្រី ថ្នាក់លេខ ៣ | ១៧/០៤/២០១៦ |
| ៦០ | លោក ជរ លឹមឈន | វរមន្ត្រី ថ្នាក់លេខ ៤ | ០១/០៤/២០១៦ |
| ៦១ | លោក សួន សារុន | វរមន្ត្រី ថ្នាក់លេខ ៤ | ១០/០៤/២០១៦ |
| **១២-ក្រសួងផែនការ** | | | |
| ៦២ | លោក អ៊ិន សុខន | វរមន្ត្រី ថ្នាក់លេខ ១ | ០៦/០២/២០១៦ |
| ៦៣ | លោក ឡាយ ផារិន | វរមន្ត្រី ថ្នាក់លេខ ២ | ១២/០២/២០១៦ |
| ៦៤ | លោក ស្វាយ សំណាង | វរមន្ត្រី ថ្នាក់លេខ ៣ | ២១/០៣/២០១៦ |
| **១៣-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | |
| ៦៥ | លោក សម្បត្តិ ណារិទ្ធ | វរមន្ត្រី ថ្នាក់លេខ ៤ | ១២/០៤/២០១៦ |
| **១៤-ក្រសួងអភិវឌ្ឍន៍ជនបទ** | | | |
| ៦៦ | លោក ហួន បូនិត | វរមន្ត្រី ថ្នាក់លេខ ១ | ០១/០៤/២០១៦ |
| **១៥-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | | | |
| ៦៧ | លោក មូល ឈន | វរមន្ត្រី ថ្នាក់លេខ ១ | ០១/០២/២០១៦ |
| **១៦-ក្រសួងធនធានទឹក និង ឧតុនិយម** | | | |
| ៦៨ | លោក ងួន យន | វរមន្ត្រី ថ្នាក់លេខ ៣ | ០១/០២/២០១៦ |
| ៦៩ | លោក ឈិត វណ្ណថា | វរមន្ត្រី ថ្នាក់លេខ ៣ | ១៧/០៣/២០១៦ |
| **១៧-ក្រសួងកិច្ចការនារី** | | | |
| ៧០ | លោកស្រី ហែម ម៉ារី | វរមន្ត្រី ថ្នាក់លេខ ៣ | ១១/០៣/២០១៦ |

| ១៨-ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | | | |
|---|---|---|---|
| ៧១ | លោក **កៅ វុឌ្ឍា** | វរមន្ត្រី ថ្នាក់លេខ **១** | ០១/០២/២០១៦ |
| ៧២ | លោក **ងុយ ហ៊ុយ** | វរមន្ត្រី ថ្នាក់លេខ **២** | ១២/០៤/២០១៦ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ១១រូប ដែលមានស្នាដៃល្អក្នុងការចូលរួមកសាងមន្ទីរពេទ្យមិត្តភាពកម្ពុជា-គូវ៉ែត ស្ថិតនៅតាមបណ្តោយផ្លូវជាតិ6A ក្នុងភូមិលើ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល កន្លងមក ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១. | លោក | TAREQ SAMI SULTAN ALEISSA |
| ២. | លោក | JAMAL KH.E.A ALHASHASH |
| ៣. | លោកបណ្ឌិត | AHMAD H.A AL JASSAR |
| ៤. | លោក | ASAAD A.A. Y ALZAWAWI |
| ៥. | លោកបណ្ឌិត | ALMUNTHER W.M.A.A ALHASAWI |
| ៦. | លោក | JASEM A.J ALHASAN |
| ៧. | លោក | ABDULRAHMAN F.S.A.A ALASFOUR |
| ៨. | លោក | SAAD M.Y.A ALKHUALIFI |
| ៩. | លោក | MOHAMMAD A.M.A ALSHARHAN |
| ១០. | លោក | KHALED A.A.A ALHENDI |
| ១១. | លោក | AHMED A.A.A ALSHUWAIB |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ [illegible]

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

[illegible]

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ [illegible]

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**-បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សប្ញទ្ធិ** ជូនមន្ត្រីរាជការ ចំនួន០២រូប នៃមន្ទីរធម្មការនិងសាសនា ខេត្តរតនគីរី និងខេត្តបន្ទាយមានជ័យ ដែលមានស្នាដៃល្អ និងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក **ពៅ ស៊ាខេខ** អនុប្រធានមន្ទីរធម្មការនិងសាសនា ខេត្តរតនគិរី

២-លោក **ស៊ាខ សេខហុក** ប្រធានការិយាល័យធម្មការនិងសាសនា ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៧ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

### សម្រេច

**មាត្រា ១.**- បំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ប្រគេនព្រះសង្ឃ និងជូនមន្ត្រីរាជការ ចំនួន ១០រូប ដែលមានស្នាព្រះហស្ត ស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ព្រះធម្មមុនី | ឆួន សុផល | ព្រះមេគណ គណៈធម្មយុត្តិកនិកាយ |
| ២- | ព្រះទីឃវ័នមុនី | គី សុបុណ្យ | ព្រះបាឡាត់គណ គណៈធម្មយុត្តិកនិកាយ |
| ៣- | ព្រះព្រហ្មបញ្ញា | ស៊ិន ច័ន្ទសុធា | ព្រះបាឡាត់គណ គណៈមហានិកាយ |
| ៤- | ព្រះបវរវេទី | អ៊ុំ ម៊ិនឆឿន | ព្រះវិន័យធរគណ គណៈមហានិកាយ |
| ៥- | ព្រះតន្តបាលធម្មោ | អ៊ឹម ឆៀង | ព្រះវិន័យធរគណ គណៈធម្មយុត្តិកនិកាយ |
| ៦- | ព្រះទីឃវ័នមេធា | គី យ៉ា | ព្រះគ្រូអនុគណក្រុងព្រៃវែង ខេត្តព្រៃវែង |
| ៧- | លោកស្រី | គឿន ពៅ | អនុប្រធានមន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែង |
| ៨- | លោក | ជ៉ោ សុវណ្ណា | អនុប្រធានមន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែង |
| ៩- | លោក | ប៊ិន សំអុល | ប្រធានការិយាល័យធម្មការ និងសាសនាស្រុកបាភ្នំ ខេត្តព្រៃវែង |
| ១០- | លោក | សំ ស៊ន់ | ប្រធានការិយាល័យធម្មការ និងសាសនាស្រុកកំពង់ត្របែក ខេត្តព្រៃវែង |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧១៣.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្តល់គ្រឿងឥស្សរិយយស

## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

